ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

ឯកសារ **D266/26 &D267/34**

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៥)

**<u>អង្គបុរេជំនុំជម្រះ</u>**

ចំពោះមុខ៖
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ៖ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
03 / 11 / 2020
ម៉ោង (Time/Heure) : 13:43
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

សាធារណៈ

**សេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អង្គបុរេជំនុំជម្រះ**
**នៅក្នុងសំណុំរឿង ០០៣**

---

**<u>សហព្រះរាជអាជ្ញា៖</u>**
ជា លាង
Brenda J. HOLLIS

**<u>សហមេធាវីការពារក្តី មាស មុត ៖</u>**
អាង ឧត្តម
Michael G. KARNAVAS

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី</u>**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

សំណុំរឿង០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)

ឯកសារ D266/26 &D267/34

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**បានទទួល**បណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ប្រឆាំងនឹង មាស មុត ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ[1] និងបណ្តឹងឧទ្ធរណ៍ចំនួនពីរប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដែលបានដាក់ដោយសហព្រះរាជអាជ្ញាជាតិ[2] និងសហមេធាវីការពារក្តី មាស មុត (ហៅរួមថា "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ")[3]។

**កត់សម្គាល់ឃើញថា** អនុលោមតាមមាត្រា ៩(១) នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ឯកសារអាចធ្វើចំណាត់ប្រភេទ និងកំណត់កម្រិតនៃការសម្ងាត់ខុសគ្នាចំពោះផ្នែកណាមួយនៃសំណុំរឿង អនុលោមទៅតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ តាមករណីសមស្រប តែប៉ុណ្ណោះ។

**កត់សម្គាល់ឃើញ**ថា កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិ ក្រោយពីបានចេញ "ដីកាលើកលែងការចោទប្រកាន់ប្រឆាំងនឹង មាស មុត[4] និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្រោយពីបានចេញដីកាដំណោះស្រាយរបស់ខ្លួន" ដោយបានចោទប្រកាន់ មាស មុត[5] បានបិទបញ្ចប់កិច្ចស៊ើបសួរ ដូច្នេះហើយសហចៅក្រមស៊ើបអង្កេត*បានបំពេញតួនាទីរបស់ខ្លួនចប់សព្វគ្រប់*។

**កត់សម្គាល់ឃើញ**ថា អង្គជំនុំជម្រះត្រូវចេញសាលដីកាជាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ អនុលោមតាមវិធាន ៧៨ នៃវិធានផ្ទៃក្នុង។

---

[1] សំណុំរឿង០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥) សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2។

[2] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3។

[3] សំណុំរឿង ០០៤/២ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4។

[4] សំណុំរឿង ០០៣ ដីកាលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

[5] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។

**កត់សម្គាល់ឃើញថា** អង្គបុរេជំនុំជម្រះកំពុងពិនិត្យសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី[6]។

**ប្រកាសថា** អង្គបុរេជំនុំជម្រះយល់ឃើញថាជាការសមស្របដែលត្រូវធ្វើចំណាត់ប្រភេទឯកសារឡើងវិញដែលពាក់ព័ន្ធនឹងដំណាក់កាលស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ ក្រោយពេលចេញសាលដីកាជាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ ជាពិសេស ត្រូវគោរពពេញលេញនូវគោលការណ៍រក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ដូចមានចែងនៅក្នុងវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះ យោងតាមសម្លេងជាឯកច្ឆ័ន្ទ÷**

**សម្រេចថា** អង្គបុរេជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០៣ ភ្លាមៗក្រោយពីចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០

**ប្រធាន** | **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** Olivier BEAUVALLET **ន៉យ ថុល** Kang Jin BAIK **ហួត វុទ្ធី**

[6] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269។